# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទថា ការបួសជាព្រះសង្ឃព្រះពុទ្ធសាសនា ចាត់ទុកជាការបណ្ដុះធនធានមនុស្ស

web site: hoksavann.org

ថ្ងៃទី២៣ មេសា ២០០៦

ការវិភាគនេះកើតឡើង ក្រោយពេលដែលសម្ដេចទេព-វង្ស ព្រះសង្ឃរាជគណៈមហានិកាយ បានប្រឆាំងនឹងការបំបួសយុវជននិងយុវតីជាង៣០០នាក់ នៅទីក្រុងភ្នំពេញ ដែលចាត់ចែងដោយអង្គការក្រៅរដ្ឋាភិបាលមួយ ឈ្មោះយុវសង្ឃពុទ្ធសាសនានៅកម្ពុជា កាលពីពីរបីសប្ដាហ៍កន្លងមកនេះ ដោយនិមន្តសម្ដេចទេព-វង្ស ជាអធិបតី ។ សម្ដេចទេព-វង្សបានមានថេរដីកាពេលនោះថា «ខ្ញុំមិនចង់ឲ្យគេយកពុទ្ធសាសនា ជាការលេងសើចទេ» ។ សម្ដេចទេព-វង្សយល់ថា ការយកយុវជននិងយុវតីមកបួសជាសាមណេរនិងសីលវតី ដើម្បីអប់រំឲ្យមានសីលធម៌ល្អ ជាភេទបរិសុទ្ធចេញផុតអំពីអំពើអបាយមុខផ្សេងៗ មានល្បែងស្រី ល្បែងស្រា ការជក់អាភៀន ជក់យ៉ាម៉ាជាដើមជាការលេងសើច ។ សម្ដេចទេព-វង្សបន្តថា «ខ្ញុំក៏ដូចជារដ្ឋាភិបាលបច្ចុប្បន្ន ចាំបាច់បំផុត គឺជាការកសាងធនធានមនុស្ស អ្វីដែលសង្គមចាំបាច់បំផុត ដើម្បីរំដោះទុក្ខរំដោះក្រ និងរំដោះអនក្ខរកម្ម» ។ យើងមិនដឹងថាសម្ដេចទេពវង្ស លោកមិនយល់ដោយសារអវិជ្ជា ឬក៏យល់ដែរតែធ្វើជាមិនយល់ ដោយមានៈចង់ប្រឆាំងនឹងអំពើល្អនេះ គឺការបណ្ដុះចិត្តគំនិតនិងចរិយារបស់កុមារាកុមារី យុវ-ជននិងយុវតី ឲ្យមានគុណធម៌ល្អ តាមរយៈការកាន់សីលចំនួន១អាទិត្យនេះ ពិតជាការបណ្ដុះធនធានមនុស្ស ។ ស្របតាមសំដីរបស់អង្គការយុវជនសង្ឃពុទ្ធសាសនាកម្ពុជាពោលថា យុវជនដែលជំរុញឲ្យបួសដោយឪពុកម្ដាយ គឺជាយុវជនដែលដើរផ្លូវខុស ញៀនគ្រឿងញៀន ។ កាលណាពួកគេស្លៀកស្បង់គ្រងចីវរ ស្លៀកសពាក់សហើយ ពួកគេមានចិត្តបរិសុទ្ធ មិនហ៊ានធ្វើអ្វីខុសទេ តែងតែស្ដាប់បង្គាប់អ្នកអប់រំ ។ ដូច្នេះការអប់រំឲ្យមានសីលធម៌នេះហើយ ជាការរំដោះទុក្ខ រំដោះភាពក្រីក្រ រំដោះភាពមិនចេះអក្សរ ព្រោះបើយុវជនយុវតីទាំងនោះ ប្រព្រឹត្តអំពើពាលនាំឲ្យមានទោ-

សជាប់ក្នុងពន្ធនាគារ នាំឲ្យម្ដាយឪពុកបង់ខាតប្រាក់កាស នាំឲ្យខាងបង់ការសិក្សារៀនសូត្រ ។ សម្ដេចទេព-វង្សបានពោលដដែលៗថា «មិនគួរបង្ខំចិត្ត ឲ្យថៅប្រុសថៅស្រីមកបួសទេ ទុកឲ្យកើតឡើងដោយញាណសម្បយុត្តរបស់គេ កូនទៅបួសទៅរៀននេះ ត្រូវគិតដល់រដ្ឋាភិបាល ការចាំបាច់បំផុត គឺធនធានមនុស្សដើម្បីដឹកនាំនិងគ្រប់គ្រងសង្គមជាតិមាតុភូមិ» ។ សំដីទាំងនេះរបស់សម្ដេចទេព-វង្សជាការឆ្លុះបញ្ចាំងកាន់តែច្បាស់ឡើងថា ព្រះអង្គយកចិត្តរដ្ឋាភិបាលខ្លាំងពេកទៅ រហូតដល់មានព្រះយោបល់ខុស ក្នុងការបណ្ដុះបណ្ដាលធនធានមនុស្ស ព្រោះគោលបំណងនៃអ្នកដែលបង្កើតឲ្យមានការបំបួសនេះ គឺកើតពីការសង្កេតឃើញថា សីលធម៌នៃយុវជនយុវនារីបានធ្លាក់ចុះ បង្កើតបងធំបងតូច រហូតដល់បង្កអំពើហឹង្សាក្នុងសង្គម ។ តាមសំដីរបស់ឪពុកម្ដាយនៃកូនអ្នកបួសពោលថា ពួកគេមានចិត្តរីករាយណាស់ ដោយបានកូនបួស គឺបានសងគុណឪពុកម្ដាយផង បានអប់រំតាមព្រះធម៌របស់ព្រះពុទ្ធសាសនា ដើម្បីឲ្យកូនជៀសវាងអំពើអាក្រក់ផ្សេងៗផង ។ ដូច្នេះឪពុកម្ដាយមានចិត្តរីករាយ ឲ្យកូនបួសដោយគ្មានការបង្ខិតបង្ខំពីជនណាឡើយ ។ ឯកូនអ្នកបួសបានពោលថា ពួកគេក៏មានចិត្តត្រេកអរក្នុងការបួសនេះ ដែលធ្វើឲ្យចិត្តពួកគេស្ងប់មិនរវើរវាយដូចមុន ហើយពួកគេសន្យាថានឹងយកសកម្មភាពដ៏ល្អថ្លៃថ្លានេះ ផ្សាយប្រាប់មិត្តភក្ដិទៀតផង ។ បើរដ្ឋាភិបាលមានបំណងកសាងធនធានមនុស្សពិតមែន ពិតជាគាំទ្រគោលគំនិតនិងសកម្មភាពយុវជននិងយុវនារីខ្មែរ តាមរយៈការបំបួសក្នុងរយៈពេលខ្លីនេះហើយ សូមសម្ដេចទេព-វង្សបញ្ឈប់ការបង្អាក់ដំណើរសកម្មភាពដ៏ល្អនេះ ដែលជាលក្ខណៈហាក់ដូចជាប្រឆាំងនឹងគោលបំណងល្អរបស់រដ្ឋាភិបាលទៅវិញ ។ តាមសំដីរបស់ស្រីម្នាក់ជាសមាជិកនៃអង្គការយុវសង្ឃពុទ្ធសាសនាកម្ពុជាពោលថា មានឪពុកម្ដាយខ្លះប្រដៅកូនមិនបាន ក៏បានប្រគល់កូនឲ្យព្រះសង្ឃជួយអប់រំ ដោយយល់ថាព្រះសង្ឃអប់រំកូនខ្លួនអាចមានប្រសិទ្ធិភាពជាងខ្លួន ។ ទីបំផុតសម្ដេចទេព-វង្សបានអំពាវនាវថា «សូមអង្គការទាំងឡាយពិចារណាឡើងវិញ អ្វីដែលត្រូវជួយខ្មែរបាន ខ្មែរចាំបាច់បំផុតយកគ្នាមកបំបួសមួយអាទិត្យមិនធម្មតាទេ ល្អមែនសីលកើតបានមែន ប៉ុន្តែកុមារខ្លះយុវជនខ្លះ កំពុងបំរើផលប្រយោជន៍ឲ្យឪពុកម្ដាយ ហើយកំពុងសិក្សារៀនសូត្រ» ។ ចម្លើយតបទៅនឹងថេរដីកាសម្ដេចទេព-វង្ស ព្រះសង្ឃមួយអង្គជាអ្នកចាត់ចែងពិធីបំបួសនេះពោលថា ព្រះអង្គបំបួសយុវជននិងយុវតីទាំងនោះក្នុងពេលវិស្សមកាល គឺពេលសំរាករៀនពីសាលា ដោយពុំបានយកពេលសិក្សាមកបំបួសឡើយ ហើយបំបួសដោយការស្ម័គ្រចិត្ត ។ តាមថេរដីការបស់សម្ដេចទេព-វង្សចុងក្រោយនេះ ហាក់ដូចជាទទួលស្គាល់ថា ការបំបួសនេះនាំឲ្យយុវជបនិងយុវតីទាំងនោះ មានសីលធម៌ពិតមែន តែហេតុអ្វីបានជាសម្ដេចទេព-វង្សប្រឆាំងនឹងមធ្យោបាយនេះ ។ ការប្រឆាំងមិនឲ្យក្មេងៗបួសនេះ វាធ្លាក់មកដល់គន្លងផែនការឆ្នាំ១៩៨០ សម័យរដ្ឋកម្ពុជារបស់គណបក្សប្រជាជនកម្ពុជា ដែល

ជាសម័យកងទ័ពវៀតណាមមកកាន់កាប់ប្រទេសកម្ពុជា ដែលពេលនោះគេអនុញ្ញាតឲ្យបួស តែមនុស្សចាស់ៗពីអាយុហាសិបចិតសិបឆ្នាំ ចំណែកក្មេងៗគេពុំអនុញ្ញាតឲ្យបួសឡើយ ។ មួយទៀតប្រឆាំងនឹងទំនៀមទំលាប់ប្រពៃណីដ៏ល្អរបស់ខ្មែរ គឺក្មេងប្រុសជំទង់ទៅបួសជាសាមណេរ បន្ទាប់មកជាភិក្ខុដើម្បីអប់រំចិត្ត បើលោកស្ថិតនៅជាព្រះសង្ឃ ធ្វើជាគ្រូជួយអប់រំសង្គមខ្មែរ បើលោកលាចាកសិក្ខាបទមកជាគ្រហស្ថវិញ បានជាពលរដ្ឋដ៏ល្អរបស់ប្រទេស ។ មួយផ្នែកទៀត ប្រឆាំងនឹងសេរីភាពអ្នកប្រតិបត្តិព្រះពុទ្ធសាសនា គឺគេចង់នៅជាគ្រហស្ថកាន់សីល៥ ឬចង់ទៅបួសក៏បានតាមចិត្តគេចង់ ពុំអាចជនណាហាមឃាត់គេបានឡើយ ព្រោះបានចែងជាច្បាប់កំពូលក្នុងរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នផ្នែកជំនឿ ។ សម្តេចទេព-វង្សបានទម្លាក់យុវជននិងយុវតីខ្មែរត្រឡប់មកសម័យខ្មែរក្រហមប្រល័យពូជសាសន៍វិញ ដោយលោកមិនចង់ឲ្យកូនចៅទាំងនោះបួស ឲ្យទៅធ្វើការបំរើឪពុកម្តាយ ក៏ដូចជាកាលសម័យខ្មែរក្រហម ឲ្យក្មេងៗធ្វើការងារពុំឲ្យរៀនសូត្រឲ្យបានពេញលេញឡើយ ។ ពិសេសទៀត សម្តេចទេព-វង្សបានប្រឆាំងនឹងឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ ដែលចង់ឲ្យកូនបួសរៀនព្រះពុទ្ធសាសនា ដើម្បីឲ្យព្រះពុទ្ធសាសនាអភិវឌ្ឍន៍ទៅមុខ ហើយជាការប្រឆាំងនឹងផែនការចតុកោណរបស់រាជរដ្ឋាភិបាលខ្មែរ ដែលកំពុងធ្វើឲ្យផ្លូវអាណាចក្រនិងពុទ្ធចក្ររីកចំរើន ស្របតាមពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។ យើងសូមអនុមោទនានូវគោលបំណងដ៏ល្អរបស់យុវសង្ឃពុទ្ធសាសនានៅកម្ពុជា ហើយសូមប្រគេននិងជូនពរសព្វសាធុការ សូមដើរទៅមុខទៀតប្រកបដោយជោគជ័យ ។

❑ ❑

❑